ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# បច្ចេកទេស
# ដាំដំណាំខ្ទឹមបារាំង



រៀបចំដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៨

# សៀវភៅ

## ស្តីពី

# បច្ចេកទេសដាំដំណាំខ្ទឹមបារាំង

## រៀបចំដោយ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
នាយកដ្ឋានសាករប្បកម្ម និងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្ម

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# មាតិកា

ទំព័រ

I. សេចក្តីផ្តើម ............................................................១
II. ប្រភពដើម.............................................................១
១. សារៈប្រយោជន៍របស់ខ្ទឹមបារាំង..................................៣
១.១ សារៈប្រយោជន៍របស់ខ្ទឹមបារាំងចំពោះសុខភាព........៣
III. ស្ថានភាពបរិស្ថាន..................................................៦
IV. បច្ចេកទេសដាំដុះដំណាំខ្ទឹមបារាំង..............................៧
១. ការជ្រើសរើសពូជ...................................................៧
២. ការជ្រើសរើសដី.....................................................៨
៣. រដូវកាលដាំដុះ......................................................៩
៤. ការរៀបចំដី.........................................................៩
៤. ១ របៀបធ្វើថ្នាលបណ្តុះកូន.......................................១០
៤. ២ របៀបសាប ឬព្រោះគ្រាប់.......................................១០
៤. ៣ របៀបប្រើប្រាស់ជីលើដំណាំខ្ទឹមបារាំង.........................១១
៤. ៤ របៀបដាំដុះ.......................................................១៣
V. ការថែទាំ..............................................................១៥
១. ការស្រោចស្រព.......................................................១៦
២. ការជ្រុំជ្រួយដី និងកំចាត់ស្មៅ........................................១៧
VI. អំពីសត្វល្អិត និងជំងឺ................................................១៨
១. សត្វល្អិតចង្រៃ.......................................................១៨
២. ជំងឺ...................................................................២០
VII. ការប្រមូលផល.......................................................២២
VIII. ការថែរក្សាទុក.......................................................២២
១. បច្ចេកទេសនៃការប្រមូលផល.........................................២៣
២. ការសំអាតក្រោយពេលប្រមូលផល...................................២៣
៣. ការជ្រើសរើសមើម...................................................២៣
៤. ការសង់រោងសម្រាប់ស្តុកទុកមើម....................................២៤
៥. ការថែទាំនៅពេលស្តុកទុក...........................................២៤

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្ដីពីដំណាំខ្ទឹមបារាំង

I. ទីប្រឹក្សាផ្ដល់យោបល់:

១. បណ្ឌិត **ហ៊ាន វណ្ណាហាន** អគ្គនាយកដ្ឋានកសិកម្ម

២. បណ្ឌិត **ម៉ៅ មិនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ហូ ពុទ្ធា** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

៤. លោក **គីម ដារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

III. អ្នកស្រាវជ្រាវ:

ក្រុមអ្នកបច្ចេកទេសពិសោធន៍ពូជបន្លែ ស្ថានីយ៍ពិសោធន៍ពូជបន្លែក្បាលកោះ

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **កេត សំអាត** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

២. លោក **ផន ប្រុស** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

៣. លោក **ជីម ចាន់ណា** នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

៤. លោក **ហុង ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៥. លោក **ឈុន សុភ័ក្រ្ត** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។



## I. សេចក្តីផ្តើម

បច្ចុប្បន្នប្រជាកសិករនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានការដាំដុះដំណាំខ្ទឹមបារាំងជាលក្ខណៈទូលំទូលាយនៅឡើយទេ។ ខ្ទឹមបារាំងដែលយើងបរិភោគសព្វថ្ងៃភាគច្រើននាំចូលមកពីប្រទេសជិតខាង។ មូលហេតុដោយសារខ្ទឹមបារាំងពិបាកដាំជាងពពួកដំណាំខ្ទឹមទាំងអស់ លើសពីនេះទៀត ការដាំដុះរបស់ប្រជាកសិករច្រើនតែជួបប្រទះនូវបញ្ហា ជាច្រើនដូចជា ជំងឺ សត្វល្អិតបំផ្លាញ និងខ្វះខាតនូវបច្ចេកទេស ព្រមទាំងកត្តារួមផ្សំមួយចំនួនផ្សេងទៀត ។



ដើម្បីជាជំនួយ ដល់ប្រជាកសិករ ក្នុងការដាំដុះ ដំណាំខ្ទឹមបារាំងឱ្យទទួលបាន ជោគជ័យ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយនាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ និងនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម បានរៀបចំចងក្រងកូនសៀវភៅបច្ចេកទេស ស្តីអំពីដំណាំខ្ទឹមបារាំងនេះឡើងដើម្បីជាជំនួយស្មារតី ផ្នែកបច្ចេកទេសជូនដល់ប្រជាកសិករឱ្យចេះដាំដុះ ដំណាំខ្ទឹមបារាំងស្របតាមបច្ចេកទេសថ្មីៗដែលអង្គភាពជំនាញបានពិសោធន៍ស្រាវជ្រាវ ។

## II. ប្រភពដើម

ខ្ទឹមបារាំង ជាដំណាំដែលមានរសជាតិ និងក្លិនប្រហើរខុសពីដំណាំឯទៀត ។ ដោយសារគុណសម្បត្តិល្អរបស់វា ទើបធ្វើឱ្យគេនិយម

ចូលចិត្ត តាំងពីយូរលង់ណាស់មកហើយនៅលើពិភពលោក ។ គេអាចប្រើប្រាស់វាបាន ដោយយកស្លឹកខ្ទឹមបារាំងមកប្រើជាបន្លែស្រស់ មួយប្រភេទយ៉ាងសំខាន់សម្រាប់បំរើការហូបចុករបស់មនុស្សរីឯមើមចាស់មកធ្វើជាគ្រឿងទេស។ ដំណាំនេះត្រូវបានគេធ្វើការដាំដុះច្រើន និងរីកសាយភាយខ្លាំងនៅក្នុងប្រទេសអ៊ីតាលី ចិន កូរ៉េ និងឥណ្ឌា ។

ក្រុមអំបូរខ្ទឹមនេះ ត្រូវបានគេអធិប្បាយថា វាមានប្រភពកំណើតនៅបែកខាងកើតនៃប្រទេសអ៊ីរ៉ង់ តាមការសិក្សា និងស្រាវជ្រាវរបស់លោក VAVILOV ១៩៥១ ។ ប្រភេទរុក្ខជាតិអំបូរខ្ទឹមមានជាង ៨០ ប្រភេទត្រូវបានគេយកទៅដាំរក្សាទុក សម្រាប់ការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលខុសៗគ្នា ដូចជានៅអឺរ៉ុបខាងកើត គឺនៅមជ្ឈមណ្ឌលរុស្ស៊ី នៅអាហ្វ្រិកខាងជើង នៅអាស៊ី និងមួយចំនួនទៀត គេយកវាទៅដាំ និងរក្សាទុកនៅប៉ែកខាងអាមេរិកខាងជើង ជាពិសេសគឺក្រុមត្រូវការធាតុអាកាសត្រជាក់ខ្លាំង នេះបើតាមការកត់ត្រារបស់លោក zeven លោក zhukovsky 1975 និងតាមកំណត់ហេតុកត់ត្រារបស់លោក Linnaeus ក្នុងឆ្នាំ ១៧៥៣ ក្រុមរុក្ខជាតិនេះមានមិនលើសពី៣១ ក្រុម ដែលគេលើកយកមកសិក្សា។ ខ្ទឹមបារាំងមានឈ្មោះធម្មតាហៅថា **Onion** ឈ្មោះវិទ្យាសាស្ត្រ **Allium cepa** វាស្ថិតនៅក្នុងគ្រួសារ **Amaryllidaceae** ។ ដំណាំនេះមានស្លឹកលក្ខណៈរាងជាបំពង់មូល នៅឆ្លាស់គ្នា ដើមរបស់វារីកប៉ោងនៅពេលអាយុកាន់តែច្រើនថ្ងៃ ជាប្រភេទដំណាំគ្មានឫសកែវ មានតែឫសរយោង លូតលាស់



យ៉ាងសកម្ម គេបរិភោគបានផ្នែកគល់ ហៅថាមើមពេលចាស់ នៅពេលខ្ចីគេបរិភោគដើម ស្លឹក ធ្វើជាប្រភេទបន្លែឆៅ។





### ១. សារៈប្រយោជន៍របស់ខ្ទឹមបារាំង

ខ្ទឹមបារាំងសម្បូរទៅដោយវីតាមីន និងជាតិកាល់ស្យូមដែលអាចឱ្យមនុស្សមានសុខភាពមាំមួន និងកម្លាំងខ្លាំងក្លា។ គេអាចយកខ្ទឹមបារាំងទៅធ្វើជាម្ហូមអាហារដូចជាយកទៅឆារ ស្ងោរ ញាំ ឬធ្វើន្លែសម្លរការី។ល។

#### ១.១ សារៈប្រយោជន៍របស់ខ្ទឹមបារាំងចំពោះសុខភាព

~ ធ្វើឱ្យសុខភាពមាត់ធ្មេញល្អ។ខ្ទឹមបារាំងជារឿយៗត្រូវបានគេប្រើសម្រាប់ បង្ការការពុកធ្មេញ និងការចម្លងរោគនៅក្នុងមាត់។ ការទំពារខ្ទឹមបារាំងឆៅ ក្នុងរយៈពេលពី ២ ទៅ ៣នាទី គឺអាចសម្លាប់នូវរាល់ប្រភេទមេរោគទាំងឡាយណា ដែលមាននៅក្នុងមាត់របស់យើង។

~ ជួយព្យាបាលនូវជំងឺបេះដូង ធ្វើឱ្យសសៃឈាមស្តើង ដោយការពារមិនឱ្យកោសិកាគ្រាប់ឈាមក្រហម បង្កើតជាដុំកំណកបាន។ ការកកស្ទះទាំងនេះ អាចធ្វើឱ្យបេះដូងអ្នក កើតមាននូវភាពមិនប្រក្រតី ឬមាននូវជំងឺសសៃឈាមបេះដូងបាន។

~ ធ្វើឱ្យស្បែកភ្លឺថ្លា ទឹកខ្ទឹមបារាំង លាយជាមួយនឹងទឹកឃ្មុំ ឬ

ប្រេងអូលីវ គឺជាឱសថដ៏ប្រសើរសម្រាប់ព្យាបាលជំងឺមុន។





~ អាចព្យាបាលនូវរាល់ការក្អក។ ការប្រើប្រាស់នូវល្បាយស្មើរគ្នា រវាងទឹកខ្ទឹមបារាំង និងទឹកឃ្មុំ គឺអាចធ្វើឱ្យអាការៈឈឺបំពង់ក និងបញ្ហានៃការក្អករបស់អ្នក មានភាពធូរស្រាល។

~ ជាឱសថសម្រាប់ជួយបន្សាបជាតិពិសរបស់សត្វល្អិត។ អ្នកអាចលាបនូវទឹកខ្ទឹមបារាំង ដើម្បីជួយបន្ថយនូវការឈឺចាប់ ដែលកើតមានដោយសារឃ្មុំទិច។ ទឹកខ្ទឹមបារាំងស្រស់ និង ល្បាយរបស់វាអាចត្រូវបានប្រើសម្រាប់លាបនៅផ្នែកខាងក្រៅ សម្រាប់ព្យាបាលនូវរាល់ការទិចពីពពួកសត្វល្អិត ឬសត្វខ្យារដំរីជាដើម។

~ ជួយសម្រាលនូវអាការៈនៃការឈឺក្រពះ ។

~ ជួយព្យាបាលនូវភាពមិនប្រក្រតីក្នុងប្រព័ន្ធទឹកម៉ូត។ សម្រាប់អ្នកដែលទទួលរងនូវអារម្មណ៍នៃការឈឺក្ដៅផ្សា ក្នុងអំឡុងពេលនៃការបត់ជើងតូច នោះខ្ទឹមបារាំងអាចជួយសម្រាលនូវស្ថានភាពនេះបាន។ អ្នកជំងឺ គួរធ្វើការផឹកទឹកខ្ទឹមបារាំងស្ងោរ ពី ៦ ទៅ ៧ក្រាម។

~ ជួយបង្ការដល់ជំងឺមហារីក។ ខ្ទឹមបារាំង គឺសំបូរទៅដោយសមាសធាតុសកម្ម ដែលអាចជួយការពារបាននូវការវិវត្តន៍ នៃកោសិកាមហារីក ។

~ ជួយសម្រាលដល់អាការៈឈឺត្រចៀក។ ទឹកខ្ទឹមបារាំងពីរ

បីតំណក់ គឺអាចត្រូវបានគេអះអាងថា វាបានជួយផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ចំពោះអ្នកដែលរងគ្រោះពីការឈឺត្រចៀកស្រួចស្រាវ។ ដោយមានស្នូរសំលេងង្វូងៗ នៅក្នុងត្រចៀក អាចនឹងត្រូវធ្វើការព្យាបាល ដោយការដាក់ដុំសំឡី ដែលបានជ្រលក់ទឹកខ្ទឹមបារាំង ចូលទៅក្នុងត្រចៀក។

ដោយយោងតាមព័ត៌មានដែលបានចុះផ្សាយក្នុងទស្សនាវដ្តីសុខភាពជាសន្តិភាព បាននិយាយថា ខ្ទឹមបារាំងគឺមានអត្ថប្រយោជន៍ក្នុងការព្យាបាលនូវជំងឺផ្សេងៗគ្នារបស់មនុស្សមានដូចជា៖ ដុំសាច់ អាការៈនៃការក្អក និង ផ្តាសាយដែលកើតមានជាបន្តរហូត ។ អ្នកជំនាញខាង





ផ្នែកឱសថសាស្ត្របានចាត់ទុកថា រុក្ខជាតិប្រភេទនេះ គឺអាចប្រើបានជាឱសថសម្រាប់ព្យាបាលនៅផ្ទះបានដោយខ្លួនឯង សម្រាប់សម្រាលនូវស្ថានភាព នៃរោគសញ្ញារបស់ជំងឺមួយចំនួន។ នៅក្នុងនោះវាក៏ត្រូវបានបញ្ជាក់ផងដែរថា ការប្រើប្រាស់នូវខ្ទឹមបារាំងនេះ គឺអាចជួយអ្នកក្នុងការបង្ការនូវជំងឺមហារីកក្រពះ និង ជំងឺមហារីកសុដន់ ។

ខ្ទឹមបារាំងគឺសំបូរទៅដោយសមាសធាតុស្ពាន់ធ័រ។តាមការ

សិក្សាស្រាវជ្រាវផ្នែកវេជ្ជសាស្ត្របានបង្ហាញថា ពពួកសមាសធាតុស្ពាន់ធ័រ គឺមាននៅក្នុងមើមខ្ទឹមបារាំង។ ទឹកខ្ទឹមបារាំងស្រស់ ត្រូវបានគេនិយាយថា វាអាចយកទៅលាបនៅលើអ្នកជំងឺដែលបាត់បង់ស្មារតី ដើម្បីជួយឱ្យពួកគេមានកំលាំង និងថាមពលបានល្អមកវិញ ។



## III. ស្ថានភាពបរិស្ថាន

ខ្ទឹមបារាំង អាចដុះលូតលាស់នៅលើដីគ្រប់ប្រភេទ ជាពិសេសដីដែលមានមមោកច្រើន ឬដីល្បាប់ដែលមានជីជាតិ ។ ហើយក៏ជាដំណាំដែលត្រូវការពន្លឺថ្ងៃពេញនិងទឹកគ្រប់គ្រាន់សម្រាប់ការលូតលាស់ផងដែរ។ ខ្ទឹមបារាំង គឺមានទំហំ ពណ៌ និង រសជាតិខុសៗគ្នា អាស្រ័យទៅតាមប្រភេទពូជ និងតំបន់ដាំដុះ។ ប្រភេទខ្ទឹមបារាំងដែលបានដាំក្នុងលក្ខខណ្ឌអាកាសធាតុក្តៅ និងអាចមានរសជាតិស្រាល ឬផ្អែម។ ខ្ទឹមបារាំងប្រភេទនេះ មានដូចជាប្រភេទពូជ Maui sweet ( គឺមានដាំនៅក្នុង ខែមេសា រហូតដល់ ខែមិថុនា) ប្រភេទ Vidalia (មានដាំនៅក្នុងខែឧសភារហូតដល់ខែមិថុនា)និងប្រភេទ Walla (មានដាំនៅក្នុងខែកក្កដា រហូតដល់ខែសីហា)។ ខ្ទឹមបារាំងដែលមានដាំនូវរដូវរងារក្នុងលក្ខខណ្ឌ អាកាសធាតុត្រជាក់





ហើយក្រោយពេលប្រមូលផល ត្រូវបានគេរក្សាទុកឱ្យស្ងួត ក្នុងរយៈពេលជាច្រើនខែ ដើម្បីឱ្យសំបកផុយស្រួយ។ ខ្ទឹមបារាំងប្រភេទនេះជាទូទៅគឺមានរសជាតិហិរជាង និងជាធម្មតាត្រូវបានគេដាក់ឈ្មោះឱ្យទៅតាមពណ៌របស់វា មានដូចជា៖ ពណ៌ស លឿង ឬ ក្រហម។ ខ្ទឹមបារាំងប្រភេទអេស្ប៉ាញ ក៏ត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់នេះផងដែរ។ បន្ថែមពីលើប្រភេទខ្ទឹមបារាំងធំៗទាំងនេះ វាក៏មានផងដែរនូវប្រភេទខ្ទឹមបារាំងតូចៗជាច្រើនប្រភេទទៀត ។

## IV. បច្ចេកទេសដាំដុះ

### ១. ការជ្រើសរើសពូជ



រូបភាពគ្រាប់



រូបភាពផ្កា

~ ត្រូវជ្រើសរើសយកពូជដែលមានគុណភាពល្អទៅដាំ ព្រោះពូជល្អអាចនាំមកនូវភោគផលល្អ មើមធំផ្តល់ទិន្នផលខ្ពស់។

~ យកពូជដែលមានរយៈពេលដាំដុះខ្លី ធន់ទ្រាំនឹងជំងឺ និងសត្វល្អិតបំផ្លាញ។

~ ជ្រើសរើសយកពូជដែលមានអត្រាដំណុះពី៨០-៩៥ %។

~ សំបកមើមក្រាស់មានរសជាតិឆ្ងាញ់។ ឧទាហរណ៍ពូជ GRANEX HYBRIDE ឬពូជ RED CREOL ដាំបានល្អនៅប្រទេសកម្ពុជាយើង ។





## ២. ការជ្រើសរើសដី

~ ត្រូវជ្រើសរើសរកដីទួលមិនលិចទឹក មានពន្លឺថ្ងៃគ្រប់គ្រាន់

~ ដីដែលដាំបានបរិមាណផលច្រើនគឺប្រភេទដីល្បាយខ្សាច់ដូចជាដីតាមមាត់ទន្លេ ឬដីដែលសំបូរជាតិផូស្វាត និងប៉ូតាស្យូម ។

~ ត្រូវរកដីធូរនៅជិតប្រភពទឹក ឬមានប្រភពទឹកគ្រប់គ្រាន់ដូចជាត្រពាំង បឹងបួ ព្រែក ស្រះ អណ្តូង ឬ នៅជិតកន្លែងមានប្រព័ន្ធធារាសាស្រ្ត ពិសេសដីដែលនៅជិតភូមិដ្ឋានដើម្បីងាយស្រួលដល់ការថែទាំស្រោចទឹកបោចស្មៅ និងការពារ ។




### ៣. រដូវកាលដាំដុះ

នៅចុងរដូវភ្លៀង គេដាំខ្ទឹមបារាំងបានដោយស្រោចទឹក។ រដូវដែលល្អជាងគេ សម្រាប់ដំណាំខ្ទឹមបារាំង គឺរដូវរំហើយដែលមានអាកាសធាតុត្រជាក់ល្អ។

### ៤. ការរៀបចំដី

- ត្រូវភ្ជួរដីឱ្យបាន២ ឬ៣ដងហើយបានជម្រៅពី ១៥ ទៅ ២០ ស.ម ។
- ត្រូវរាស់បំបែកដីឱ្យម៉ដ្ឋល្អដើម្បីឱ្យខ្យល់អាកាសចេញចូលបានស្រួល ទឹកងាយជ្រាបចូល រក្សាសំណើមបានយូរនិងអាចឱ្យឫសខ្ទឹមបារាំងអាចស្រូបយកជីជាតិបានល្អ។




## ៤. ១ របៀបធ្វើថ្នាលបណ្ដុះកូន

### ❋ ការរៀបចំដី

~ ភ្ជួរដីឱ្យបាន ២ទៅ ៣ដង និងមានជម្រៅពី ១៥ ទៅ ២០ ស.ម

~ ធ្វើដីឱ្យបានម៉ដ្ឋល្អ ដើម្បីឱ្យខ្យល់ចេញចូលបាន ងាយជ្រាបទឹករក្សាសំណើមដីបានយូរ និងធ្វើឱ្យឫសចាក់ចូលជ្រៅងាយស្រូបយកជីជាតិពីក្នុងដី។





### ❋ ការរៀបចំរង

~ ថ្នាលសាបត្រូវមានទទឹង ១ម និងបណ្ដោយតាមលទ្ធភាពដី

~ កំពស់ថ្នាលសាប ចាប់ពី ២តឹកទៅ២តឹកកន្លះ សម្រាប់រដូវប្រាំង និងពី ២ ទៅ ៣ តឹកសម្រាប់រដូវវស្សា។

### ❋ ការប្រើប្រាស់ជី

~ ត្រូវដាក់ជីលាមកគោចំនួន ៣គីឡូក្រាម ក្នុងដី ១ម៉ែត្រការ៉េ

~ ជី ២០-២០-១៥ ចំនួន ៣០ ក្រាម ក្នុងដី ១ម៉ែត្រការ៉េ

~ ជី អាចម៍មាន់ចំនួន ៣០០ ក្រាម ក្នុងដី ១ម៉ែត្រការ៉េ

~ ត្រូវក្រាលចំបើងស្ដើងៗនៅពីលើថ្នាល

គេអាចបណ្ដុះគ្រាប់ខ្ទឹមបារាំងនៅក្នុងឡាំង ឬកេសឈើដែលងាយស្រួលដល់ការលើកដាក់ចុះឡើង ។

## ៤. ២ របៀបសាប ឬព្រោះគ្រាប់

ត្រូវយកគ្រាប់ខ្ទឹមបារាំង ទៅលាយជាមួយដីខ្សាច់ម៉ដ្ឋ ឬផេះ(គ្រាប់ពូជ

មួយភាគលាយដីខ្សាច់ ឬ ផេះបួនភាគ)រួចយកទៅសាបឬព្រួសឱ្យស្តើងៗលើថ្នាល។ គ្រាប់ខ្ទឹមបារាំងចំនួន៣ក្រាម លាយជាមួយដីខ្សាច់ម៉ដ្ឋឬផេះ ១២ក្រាម (មួយភាគបួន )។ ក្រោយពេលសាបរួចត្រូវកាត់ចំបើងខ្លីៗទៅគ្របពីលើ ដើម្បីរក្សាសំណើមលើថ្នាលបានយូរ។ ត្រូវស្រោចទឹកឱ្យបាន ៣ ដងក្នុង១ ថ្ងៃដោយប្រើធុងដែលមានជំពួយផ្កាឈូកជៀសវាងគ្រាប់ខ្ទាតកកជុំៗ។ត្រូវយកផេះរោយជុំវិញថ្នាលការពារស្រមោចចូលស៊ីគ្រាប់ខ្ទឹម។ត្រូវគ្របថ្នាលលុះត្រាតែកូនខ្ទឹមបារាំងដុះចេញពន្លកទើបបើកចេញបាន។

- ករណីខ្លះគេអាចសាបផ្ទាល់លើរងតែម្តង តែត្រូវសាបឱ្យស្មើ និងស្តើងៗ បើធ្វើរបៀបនេះត្រូវដកកូនខ្ទឹមបារាំងដែលអន់មានជំងឺ និងសត្វល្អិតបំផ្លាញចេញ ហើយទុកតែមួយដើមក្នុងមួយគុម្ព នៅពេលកូនខ្ទឹមបារាំងដុះបានពី ៧ ទៅ ១០ថ្ងៃ។





### ៤. ៣ របៀបប្រើប្រាស់ជីលើដំណាំខ្ទឹមបារាំង

ក្រោយពេលធ្វើថ្នាលបានត្រឹមត្រូវហើយ ត្រូវយកជីមករាយឱ្យស្មើរួចកាប់ត្រឡប់ទៅក្នុងដីរាស់ឱ្យស្អាត ។

**កម្រិតជីត្រូវប្រើ:**

ការដាក់ជីមាន ២ របៀប

- ការប្រើលើដីទំហំ១ម៉ែត្រការ៉េ ៖

**របៀបទី ១ :**

ដាក់លើកទី១ : មុនពេលលើករងដាំ ឬទ្រាប់បាត

- ជីលាមកសត្វ គោ ក្របី ចំនួន ៣ ទៅ ៥ គីឡូក្រាម ក្នុង១ម៉ែត្រការ៉េ
- ជីផេះ ចំនួន ១០០ ក្រាម ក្នុង១ម៉ែត្រការ៉េ
- ជីគីមីកែងលេខ (១៥.១៥.១៥) ចំនួន ៣០ ទៅ ៥០ ក្រាម ក្នុង១ម៉ែត្រការ៉េ




លើកទី២ : ប្រើសម្រាប់បំប៉នពេលខ្ទឹមបារាំងចាប់ផ្ដើមចេញមើម (ក្រោយស្ទូង១ខែ)

- ដាក់ជីគីមីកែងលេខ(១៥.១៥.១៥) ចំនួន ៣០ ក្រាមក្នុង១ម៉ែត្រការ៉េ
- ស្រោចជីអ៊ុយរ៉េ ២ ស្លាបព្រាបាយលាយជាមួយទឹក ២០ លីត្រ (១អាទិត្យស្រោច១ដង ចាប់ស្រោចពេលដាំរួច )។



របៀបទី ២ :

លើកទី ១ : មុនពេលលើករងដាំ ឬទ្រាប់បាត

- ជីអាចម៍មាន់ចំនួន៣០០ ក្រាមក្នុង១ម៉ែត្រការ៉េ
- ជីគីមីកែងលេខ(១៥.១៥.១៥) ចំនួន៣០ក្រាមក្នុង១ម៉ែត្រការ៉េ

លើកទី ២ : ប្រើសម្រាប់បំប៉នក្រោយពេលដាំ ១ ខែ

- ជីកែងលេខ (១៥.១៥.១៥) ចំនួន ៣០ ក្រាមក្នុង១ម៉ែត្រការ៉េ
- ជីអ៊ុយរ៉េ ២ ស្លាបព្រាបាយលាយទឹក ២០ លីត្រស្រោច ១ អាទិត្យម្តងក្រោយពេលដាំរួច ១ សប្តាហ៍ ។

បរិមាណជីប្រើប្រាស់សម្រាប់ផ្ទៃដី១ ហិកតា៖

- ទ្រាប់បាតមុនពេលដាំ ជីកំប៉ុស្ត ១៥តោន ក្នុងមួយហិកតា
- ជី DAP ចំនួន ១៥០ គីឡូក្រាមក្នុងផ្ទៃដី១ហិកតា
- បំប៉នក្រោយពេលស្ទូងបានរយៈពេល ១៥ថ្ងៃ គឺបំប៉នជីអ៊ុយរ៉េ ចំនួន ៦០គីឡូក្រាម ក្នុងមួយហិចតា
- បំប៉នតាមចន្លោះគុម្ព ប្រភេទជីកែងលេខ (១៥.១៥.១៥) ចំនួន ២០០គីឡូក្រាមក្នុងមួយហិកតា ក្រោយដាំរយៈពេល ៣០ទៅ៣៥ថ្ងៃ។
- បំប៉នតាមចន្លោះគុម្ពប្រភេទជីកែងលេខ (១៥.១៥.១៥) ចំនួន ១០០គីឡូក្រាម និងលាយជាមួយជីកាលី(០.០.៦០) ចំនួន ៥០ គីឡូក្រាម និងជីអ៊ុយរ៉េ(៤៦.០.០)ចំនួន ៤៨គីឡូក្រាម ខ្ទឹមឡើងមើម គឺអាយុ ៥៥-៦៥ ថ្ងៃ តាមប្រភេទពូជ ។

**កំណត់សម្គាល់៖**

ខ្ទឹមបារាំងត្រូវការចាំបាច់នូវសារធាតុប៉ូតាស្យូមដើម្បីបង្កបង្កើតមើមបានធំល្អ។ ជីជាតិប៉ូតាស្យូមអាចមានច្រើននៅក្នុងផេះសំបកគរ។ល។

### ៤. ៤ របៀបដាំដុះ

គេអាចធ្វើការដាំដុះខ្ទឹមបារាំងនៅចុងរដូវភ្លៀង ដោយស្រោច

ស្រពជាប្រចាំ។រដូវដែលល្អជាងគេសម្រាប់ការដាំដុះដំណាំខ្ទឹមបារាំង គឺ នៅរដូវរំហើយ ពីព្រោះរដូវនេះមានអាកាសធាតុត្រជាក់ល្អ ។

ក្រោយពីលើករងហើយ ត្រូវរៀបចំរងនោះដូចពេលសាបគ្រាប់ដែរ បន្ទាប់មកទៀតត្រូវដកកូនពីថ្នាលដោយថ្នមៗ មិនឱ្យដាច់ឫសឬបាក់ដើម ដាក់ក្នុងឧបករណ៍ដូចជាកញ្ជើ ល្អី ។ល។ ហើយស្រោចទឹកឱ្យជោគល្អមពីពេលព្រឹករហូតដល់ពេលល្ងាចទើបយកកូនខ្ទឹមទៅស្ទូងបាន។





ត្រូវដកកូនខ្ទឹមបារាំងយកទៅដាំនៅពេលរសៀលត្រជាក់ដើម្បីកុំឱ្យកូនខ្ទឹមស្វិតឬស្លោកដោយសារកំដៅថ្ងៃ។ គេអាចដកកូនខ្ទឹមបារាំងទៅដាំនៅពេលវាមានអាយុ ៣០ ទៅ ៣៥ ថ្ងៃ គឺនៅពេលឃើញមានស្លឹក ៣ទៅ៤ ហើយជ្រើសយកកូនណាដែលល្អ ដើមធំរឹងមាំគ្មានជំងឺ ឬ






សត្វល្អិតបំផ្លាញ។ ក្រោយពេលដាំរួចភ្លាម ត្រូវគ្របឱ្យបាន៣ថ្ងៃដើម្បីឱ្យដីរក្សាសំណើមបានយូរ។ ត្រូវទុកចន្លោះគុម្ព០,១០ ម៉ែត្រ និងចន្លោះជួរ ០,១៥ ម៉ែត្រ ។

យើងអាចធ្វើការដាំដុះបានដែរ ដោយដំបូងគេត្រូវពង្រាបដីលើរងឱ្យស្មើ ហើយវាយបំបែកដីឱ្យម៉ដ្ឋល្អ បន្ទាប់មកបាចជីកំប៉ុស្ត ជីគីមី និងថ្នាំសម្លាប់សត្វល្អិតទៅលើរងដូចជាថ្នាំ ហ្វុយរ៉ាដង់(Furadan) ចំនួន ២៥ ទៅ ៣០ក្រាម លើផ្ទៃដី ១៥ម៉ែត្រការ៉េ ហើយរាស់លប់ ឱ្យជិតនៅក្នុងដី បន្ទាប់មកទៀតយកគ្រាប់ពូជទៅលាយជាមួយថ្នាំផ្សិតដូចជាថ្នាំ ខាប់ថេន (Captan ) ២-៣ក្រាម ហើយសាបទៅលើថ្នាល១៥ ម៉ែត្រការ៉េដោយប្រើគ្រាប់ពូជពី ១០ ទៅ ១៣ក្រាម។ ពេលខ្លះគេយកគ្រាប់ពូជទៅត្រាំទឹក ឬត្រាំសូលុយលុងសូល្យូមផូស្វាត (sodium phos phate )២-៤ ម៉ោង ហើយហាលសម្ងួតគ្រាប់ពូជ ឱ្យស្ងួតបន្តិចទើបលាយជាមួយថ្នាំផ្សិត។ គ្រាប់ពូជយកទៅសាបអាចពី ៨ ទៅ ៩ គីឡូក្រាមក្នុង ១ ហិកតា ក្រោយពីសាបហើយត្រូវយកកំទេចចំបើងស្ងួតព្រាចពីលើការពារកុំឱ្យក្តាំងដី  បន្ទាប់មកទៀតធ្វើដំបូលដោយប្រក់ក្រណាត់ពណ៌ស ឬសំណាញ់ការពារកំដៅថ្ងៃនិងទឹកភ្លៀង។

## V. ការថែទាំ

ក្រោយពីសាបរយៈ៨ទៅ១០ថ្ងៃ ខ្ទឹមចាប់ផ្តើមដុះសន្លឹកចេញមួយ





ត្រង់ទៅលើ ពេលនោះត្រូវបើកគម្របចេញ ចាប់ពីពេលព្រឹករហូតដល់ថ្ងៃត្រង់ ទើបគ្របគម្របនោះវិញ ធ្វើរបៀបនេះរហូតដល់រយៈពេល៣ថ្ងៃ

ក្រោយពេលដុះ មិនចាំបាច់គ្របទៀតទេ ក្នុងករណីមិនមានភ្លៀងធ្លាក់ ។

~ អាយុកាលលូតលាស់ ដំបូងចាប់ពីបណ្តុះរហូតដល់កូនខ្ទឹមបារាំងមានអាយុ២៥ ទៅ ៣០ ថ្ងៃ ត្រូវធ្វើការបាញ់ថ្នាំផ្សិត លាយជាមួយថ្នាំពុល១សប្តាហ៍ម្តង ដើម្បីការពារការរលួយកូនខ្ទឹមបារាំង ។



~ ក្រោយពីកូនខ្ទឹមបារាំងមានអាយុ ៦អាទិត្យ អាចដករំលួសកូនចេញខ្លះ ដោយទុកឱ្យកូនខ្ទឹម មានចន្លោះឃ្លាតពីគុម្ពមួយទៅគុម្ពមួយប្រមាណ ១៥ ស.ម ដោយមួយម៉ែត្រការ៉េត្រូវទុកត្រឹមតែ៣០ដើម នេះជាចន្លោះគុម្ពដែលអាចឱ្យកូនខ្ទឹមបារាំងលូតលាស់បានល្អ ។

~ ក្រោយស្ទូង ៧៥ ទៅ ៨០ថ្ងៃ ស្រោចជីអ៊ុយរ៉េ (៤៦.០០.០០) បំប៉ន។

## ១. ការស្រោចស្រព

~ ស្រោចទឹក ពេលព្រឹកល្ងាច ជ្រោយដីដើម្បីឱ្យខ្យល់ចេញចូលបានស្រួលទឹកងាយជ្រាបចូលក្នុងដីរក្សាសំណើមបានយូរឱ្យឫសខ្ទឹមបារាំងអាចស្រូបយកជីជាតិបានល្អ ។



ការថែទាំ ជាការងារចាំបាច់បំផុតសម្រាប់ដំណាំខ្ទឹមបារាំង ដើម្បីបង្កើនទិន្នផលខ្ពស់ ព្រោះស្មៅវាអាចប្រជែងដណ្តើមស្រូបយក ជីជាតិពីដី ។

## ២. ការផ្រុំជ្រួយដី និងកំចាត់ស្មៅ

～ ការជ្រួយដីធ្វើឡើង ក្រោយពីដំណាំខ្ទឹមបារាំងមានអាយុ២៥ថ្ងៃ គឺចាប់ផ្តើមដកស្មៅ និងជ្រួយដីជាលើកដំបូង ដើម្បីឱ្យដីផុស និងសំណើមដីមានលំនឹង លុះក្រោយមកគេដកស្មៅចង្រៃនោះចេញដោយមិនចាំផ្រុំដីនោះទេ។ ការថែទាំរួមមាន ការបោចស្មៅសំអាតតាមរងដំណាំ ឬថ្នាលបណ្តុះគ្រាប់ ។ ត្រូវបោចស្មៅឱ្យបាន ២ ឬ ៣ ដង អាស្រ័យតាមសភាពជាក់ស្តែងនៅក្នុងចម្ការ។ ក្រោយពីធ្វើស្មៅស្អាត យើងអាចដាក់ជីបំប៉នដើម្បីជំរុញដល់ការដុះលូតលាស់របស់ខ្ទឹមបារាំង ។ ចំពោះការស្រោចទឹកត្រូវស្រោចឱ្យបានទៀងទាត់ មិនឱ្យសើមពេក ឬក៏ស្ងួតពេកនោះទេ ។

～ ដកស្មៅ និង ស្រោចជីបំប៉ន ជាលើកដំបូងពេលកូនខ្ទឹមបារាំងមានអាយុ ២៥ថ្ងៃ ក្រោយសាប ប្រើជីអ៊ុយរ៉េចំនួន១០ក្រាម លាយជាមួយទឹក១០លីត្រ ស្រោចលើផ្ទៃដី១៥ម៉ែត្រការ៉េ ហើយស្រោចទឹកលាងតាមក្រោយជាធម្មតា ។




## VI. អំពីសត្វល្អិត និងជំងឺ

### ១. សត្វល្អិតចង្រៃ

ដោយសារខ្ទឹមបារាំងមានរសជាតិហិរ បណ្ដាលឱ្យសត្វល្អិតចង្រៃពុំសូវបំផ្លាញជាលក្ខណៈធ្ងន់ធ្ងរនោះទេ។ តែគេនៅតែសង្កេតឃើញដង្កូវពីរប្រភេទដែលបំផ្លាញដូចជា៖

**- ដង្កូវស៊ីរូងស្រទាប់ស្លឹក ឬដង្កូវស៊ីរូងស្លឹក**





**- ទ្រីប :** ទ្រីបតូចៗមានពណ៌ស ការបំផ្លាញរបស់វាគឺជញ្ជក់ស្លឹកខ្ទឹមបារាំង ហើយបង្កជាជំងឺវីរុស លើដើម និងមើមខ្ទឹមបារាំងតែម្ដង។

**- ដង្កូវស៊ីញៀ:** ការបំផ្លាញរបស់វា គឺជញ្ជក់នៅលើស្លឹកខ្ទឹមបារាំងទីបំផុតធ្វើឱ្យដើម ឬស្លឹកខ្ទឹមបារាំងងាប់។

**វិធីការពារនឹងកំចាត់៖**

គេអាចកំចាត់ដង្កូវប្រភេទនេះបាន ដោយប្រើថ្នាំដែលមានធាតុសកម្មឈ្មោះ (ដាយណូធីហ្វីរ៉ង) (គ្លរ៉ានតានីលីប្រ៊ុល) ថ្នាំម៉ាឡាចុងកម្រិតប្រើ៤ស្លាបព្រាបាយលាយទឹក២០លីត្រឬទឹកមួយប៉ោតប្រេងកាតចំពោះការប្រើ អាចមើល តាមការណែនាំ បន្ថែមទៀត ដូចមានបង្ហាញជូននៅលើកញ្ចប់ ឬដប់ថ្នាំ។ គេអាចកំចាត់វា ដោយប្រើថ្នាំពុលហ្វូសឌ្រីន

ឬមេដាំហ្វូស ២ស្លាបព្រាបាយលាយជាមួយទឹក២០លីត្រ ឬមួយធុងបាញ់ថ្នាំ ហើយបាញ់លើកន្លែងដែលមានការបំផ្លាញពីពពួកសត្វល្អិតខាងលើ។ ក្រៅពីនេះ គេក៏អាចប្រើបាននូវប្រភេទថ្នាំ ដែលមានធាតុសកម្មដូចជា Fipronil, Chlorantraniliprole, flubendiamide, chlorrpyrifos, Emamectin, benzoate, Bacillus thuringrensis..។ ដោយសារដើមខ្ទឹមបារាំងមានលក្ខណៈជាបំពង់ និងមានស្រទាបស្លឹកមានលក្ខណៈជារំអិលផងនោះ ទើបការប្រើប្រាស់ថ្នាំកម្ចាត់ពពួកដង្កូវលើដំណាំខ្ទឹមបារាំង មានការលំបាក តែដើម្បីឱ្យថ្នាំមានប្រសិទ្ធភាពកាន់តែខ្ពស់ យើងគួរយកថ្នាំទាំងនោះមកលាយជាមួយប្រេងបញ្ច្រាប (Citrus oil ឬ Alcohol ethoxylate..)បន្ថែមទៀត។

**ដង្កូវរុយ:** ការបំផ្លាញរបស់វាគឺកាត់ស្លឹក និង ចោះស្លឹក ។










### វិធីការពារនិងកំចាត់៖

គេកំចាត់ដង្កូវប្រភេទនេះដោយប្រើថ្នាំដែលមានធាតុសកម្មឈ្មោះ អេម៉ាមិចទីន និង ថ្នាំអាបាមិចទីន (Abamachtin) និងថ្នាំហ្វូសគ្រីន (Phosdrin) ឬ មីវិនហ្វូស (Mevinphos) កម្រិតប្រើ២ស្លាបព្រាបាយលាយទឹក២០លីត្រ ឬមួយធុងបាញ់ថ្នាំ។

ចំពោះការប្រើ អាចមើលតាមការណែនាំន្ថែមទៀត ដែលមានបង្ហាញជូននៅលើកញ្ចប់ ឬ ដប់ថ្នាំដើម្បីជៀសវាងការប្រើប្រាស់ខុសបច្ចេកទេស និងពុំមានប្រសិទ្ធភាព នាំឱ្យខាតបង់ថវិកា។

## ២. ជំងឺ

ឆ្លងកាត់ការដាំដុះកន្លងមក គេតែងសង្កេតឃើញមានជំងឺមួយចំនួនកើតនៅលើខ្ទឹមបារាំងជំងឺទាំងនោះច្រើនបណ្តាលមកពីពពួកផ្សិត បាក់តេរី និងវីរុស។

ជំងឺផ្សិត ដែលតែងតែធ្វើឱ្យកូនខ្ទឹមបារាំងរលួយ ពិសេសនៅពេលខ្ទឹមបារាំងអាយុបាន ២៨ ទៅ ៣៥ ថ្ងៃ ឬដុះបានស្លឹក ៣ ក្រោយសាប។ ភ្នាក់ងារបង្កឱ្យរលួយគល់នេះមានឈ្មោះ Alrernariaspp ការបំផ្លាញធ្វើឱ្យកូនខ្ទឹមបារាំងដុះផ្សិតនៅតាមគល់ ហើយអាចឆ្លងពីដើមមួយទៅដើមមួយទៀត យ៉ាងឆាប់រហ័ស ពេលសំណើមបរិយាកាសផ្តើមពី ៧០



កូនខ្ទឹមបារាំងទទួលរងការបំផ្លាញពីជំងឺផ្សិត

ទៅ ៩០% ឬសំណើមជោគជាំខ្លាំង។

**វិធីការពារនឹងកំចាត់ ៖**

ប្រើថ្នាំម៉ាណេប (Maneb) M- 45 ឬ ថ្នាំដាយថាន (Dithan) M-45 លាយជាមួយទឹកបាញ់ពេលសំណើមបរិយាកាសឡើងខ្ពស់ ឬពេលមានក្លិនខ្ទឹមក្នុងចម្ការ ឬថ្នាលបណ្តុះ ។

~ ជំងឺផ្សិតលើមើម ឈ្មោះ Stem phylium Blight ជំងឺនេះធ្វើឱ្យមើមខ្ទឹម ផ្នែកខាងក្រោមរលួយឫសឡើងពណ៌ខ្មៅ គេឱ្យឈ្មោះថា Basal Rot ជំងឺនេះភាគច្រើនបណ្តាលមកពីកំដៅដីឡើងខ្ពស់ គួបផ្សំជាមួយនឹងសំណើមបរិយាកាស បានបង្កលក្ខណៈអំណោយផលដល់ការលូតលាស់ដល់មេរោគប្រភេទនេះ ។





មើមខ្ទឹមបារាំងទទួលរងការបំផ្លាញពីជំងឺផ្សិត

**វិធីការពារនឹងកំចាត់**

~ បាញ់ថ្នាំពពួកថ្នាំផ្សិត លើគ្រាប់ពូជ និងដំណាំកំពុងលូតលាស់

~ គាស់ ដក ឬ ដុតចោល ឱ្យឆ្ងាយពីចំការពេលឃើញមានកើតជំងឺនៅលើដើម ឬគុម្ពណាមួយ។

~ ជ្រើសរើសពូជដែលធន់ទ្រាំនឹងជំងឺ

- ការផ្លាស់ប្តូរមុខដំណាំលើដីតែមួយកន្លែងជាវិធីល្អ
- ហាលដីឱ្យស្ងួតមុនពេលដាំ។

## VII. ការប្រមូលផល

គេអាចប្រមូលផល បាននៅពេលដែលស្លឹករបស់វាចាប់ផ្តើមងាប់ សំបកមើមឡើងពណ៌ក្រហម ឫស និងមើមលេចចេញពីដី ពូជខ្លះមានរយៈពេលលូតលាស់ពី១២០-១៧០ថ្ងៃ ក្រោយពេលសាប។ ទិន្នផលខ្ទឹមបារាំងអាចផ្តល់ជាមធ្យមពី៣០ ទៅ ៧០ តោនក្នុង១ហិកតា ។









## VIII. ការថែរក្សាទុក

ចង់រក្សាមើមខ្ទឹមបារាំងទុកបានយូរថ្ងៃ ត្រូវទុកទាំងស្លឹក រួចចងជាដុំព្យួរឱ្យផុតពីដីដាក់នូវកន្លែងដែលមានអាកាសធាតុត្រជាក់មានខ្យល់ចេញចូលល្អ មានសីតុណ្ហភាពក្រោម១០ អង្សាសេ។ នៅប្រទេសកម្ពុជាយើង ពុំអាចរក្សាពូជខ្ទឹមបារាំងបានល្អទេ ដោយសារអាកាសធាតុពុំសមស្រប និងសេចក្តីត្រូវការសម្រាប់ពូជខ្ទឹមបារាំង។ ចំពោះមើមខ្ទឹមបារាំង

មិនសូវល្អ ត្រូវរើសដាក់មុំ ដើម្បីបញ្ចេញលក់ឱ្យទាន់ពេលវេលា។





### ១. បច្ចេកទេសនៃការប្រមូលផល

តាមធម្មតាខ្ទឹមបារាំង គេអាចប្រមូលផលនៅពេលដែលវាមានអាយុពី៣ទៅ៤ ខែក្រោយពីដាំហើយ នៅពេលនោះគេសង្កេតឃើញថាដើម (ស្លឹក)របស់វាត្រង់កន្លែងក្បែរមើមទន់បាក់ក ទើបគេចាប់ប្រមូលផល។ តែបើស្លឹករបស់វា(ដើម) នៅត្រង់ យើងមិនអាចប្រមូលផលបានទេព្រោះខណៈពេលនេះខ្ទឹមបារាំងនៅមានជាតិទឹកច្រើនយើងមិនអាចរក្សាទុកបានយូរទេ ។

### ២. ការសំអាតមើមខ្ទឹមបារាំងក្រោយពេលប្រមូលផល

ក្រោយពេលប្រមូលផលហើយ មិនត្រូវយកមើមទៅលាងទឹកទេ ត្រូវទុកទាំងជាប់ដីតិចៗ ហើយកាត់ឫសចេញខ្លះ តែយ៉ាងណាកុំឱ្យកាត់ទៅដល់គល់ឫស ។ បើយើងកាត់ដល់គល់ឫសការរក្សាទុកក៏មិនបានយូរដែរ វាឆាប់រលួយមើម ។

### ៣. ការជ្រើសរើសមើម

ក្រោយពេលសំអាត ត្រូវជ្រើសរើសមើមណាដែលល្អទុកមុំ ចំពោះមើមណាដែលកាត់ហើយមានជាប់ដើម (បណ្តូលស្លឹក) ដែលមានពណ៌លឿង ឬមើមណាដែលចង់រលួយ ជាពិសេសយើងសង្កេតឃើញថាមិនសូវល្អត្រូវជ្រើសរើសដាក់មុំ ដើម្បីបញ្ចេញលក់ឱ្យទាន់ពេលវេលា ។ ព្រោះ

បើសិនជាយើងមិនបានជ្រើសរើស ហើយរក្សាទុកវាលាយគ្នា អាចបណ្តាលឱ្យខូចគុណភាពដល់មើមដែលល្អទៀត។

## ៤. ការសង់រោងសម្រាប់ស្តុកទុកមើម

ចំពោះការស្តុកទុក អាចសង់រោងមួយប្រក់ដោយស្លឹក និងមានជញ្ជាំងស្លឹក ហើយចំហទ្វារសងខាងដើម្បីឱ្យមានខ្យល់ចេញចូល ។ នៅក្នុងរោងមានធ្វើធ្នើរ ៣ ជាន់ ធ្នើរធ្វើពីរនាបឫស្សី ។ កម្ពស់ពីធ្នើរមួយទៅមួយប្រវែងពី៧តឹកទៅ១ម៉ែត្រ ដើម្បីឱ្យស្រឡះ និងមានខ្យល់ចេញចូលល្អ ។





*រោងសម្រាប់ស្តុកទុកមើមខ្ទឹមបារាំង*

## ៥. ការថែទាំមើមខ្ទឹមបារាំងនៅពេលស្តុកទុក

នៅពេលស្តុកមើមខ្ទឹមបារាំងទុក ត្រូវដាក់មើមពង្រាយជៀសវាងដាក់មើមគរលើគ្នា ហើយឧស្សាហ៍ទៅពិនិត្យមើល ប្រសិនបើមានឃើញ





មើមណារលួយត្រូវដកវាចេញ ព្រោះថាបើយើងមិនធ្វើដូច្នេះទេនាំឱ្យមើមខ្ទឹមបារាំងរលួយទាំងអស់ ។ ការចុះទៅត្រួតពិនិត្យនៅកន្លែងស្តុកទុករយៈពេល៣ថ្ងៃម្តងត្រូវធ្វើឡើងជាប្រចាំ ជៀសវាងការខូចខាត ។

ហេតុផលនៃការរក្សាទុកយូរនេះ គឺដើម្បីឱ្យតម្លៃខ្ទឹមបារាំងឡើងខ្ពស់បន្តិច ព្រោះបើយើងប្រមូលផលភ្លាមលក់ភ្លាមនាំឱ្យតំលៃខ្ទឹមបារាំងបានថោក ដោយការប្រមូលផលត្រូវធ្វើឡើងក្នុងពេលជាមួយគ្នា ។

**វិធីសាស្ត្រសំខាន់ៗនៃការប្រមូលផល និងរក្សាទុកក្រោយពេលប្រមូលផលមានៈ**

- ប្រមូលផលនៅពេលខ្ទឹមបារាំងមានអាយុពី ៣ - ៤ ខែ និងពេលដែលយើងសង្កេតឃើញថាស្លឹករបស់វាបាក់នៅត្រង់កន្លែងក្បែរគល់
- ត្រូវសំអាតខ្ទឹមក្រោយពេលប្រមូលផល ដោយកាត់ឫសចេញខ្លះ តែកុំកាត់ឱ្យដោយគល់ឫស និងកុំលាងទឹកនាំឱ្យការរក្សាទុកមិនបានយូរ ។
- ក្រោយពីកាត់សំអាតឫសហើយ ត្រូវធ្វើចំណាត់ថ្នាក់មើមខ្ទឹមបារាំងដែលល្អទុកមួយផ្នែក និងមើមដែលយើងសង្កេតឃើញថាមិនល្អ ដូចជាបណ្តូលដើមមានពណ៌លឿង មើមចង់រលួយទុកមួយផ្នែកដើម្បីបញ្ចេញលក់ឱ្យបានឆាប់រហ័ស ។
- ចំពោះមើមល្អៗ ត្រូវរក្សាទុកនៅលើធ្នើរប្រក់ដំបូល និងមានខ្យល់ចេញចូល ។
- ក្នុងការស្តុកទុក ត្រូវពង្រាយមើម មិនត្រូវដាក់មើមគរលើគ្នាទេ នាំឱ្យហាប់ខ្យល់ឆាប់រលួយ ។
- ពេលស្តុកមើមទុក ត្រូវឧស្សាហ៍វែកត្រួតពិនិត្យមើលមើមណារលួយ ឆាប់ដកចេញ ដើម្បីកុំឱ្យរាលដាល ដល់មើមដទៃទៀត ( ត្រូវត្រួតពិនិត្យ ២ ទៅ ៣ ថ្ងៃម្តង )៕

## ឯកសារយោង៖


១. កូនសៀវភៅបច្ចេកទេសស្តីពីដំណាំខ្ទឹមបារាំង, ២០០៣

២. ស្ថានីយ៍ពិសោធន៍ពូជបន្លែក្បាលកោះ, ២០០៧

៣. ទស្សនាវដ្តីសុខភាព, ឆ្នាំ ២០១៧






ក្រុមការងារចងក្រង កូនសៀវភៅបច្ចេកទេសកសិកម្ម ស្តីអំពីដំដាំខ្ទឹមបារាំង សង្ឃឹមថាការបោះពុម្ពផ្សាយកូនសៀវភៅបច្ចេកទេសកសិកម្ម ជាលើកទី១នេះ ពិតជានៅមានការខ្វះចន្លោះ ទាំងបច្ចេកទេស រូបភាព និងអក្ខរាវិរុទ្ធ ជាមិនខានឡើយ រាល់ការខ្វះខាតទាំងនេះ ក្រុមការងារយើងខ្ញុំ សង្ឃឹមថា នឹងទទួលបាននូវការជួយកែលំអ បំពេញបន្ថែម ពីសំណាក់ប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន រាល់ការកែលំអទាំងអស់នោះ ក្រុមការងារយើងខ្ញុំ នឹងយកទៅចងក្រងសម្រាប់ការបោះពុម្ពផ្សាយជាលើកទី២បន្តទៀត ៕










**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : ០១២ ៩២ ៦៨ ៩២/០៩៥ ៩៥២ ២៨១/០៨៩ ៩០៦ ២៤២

**ទូរសារលេខ** : ០២៣ ២១ ០៩ ៤៨

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម/Department of Agricultural Extension

**គេហទំព័រ** : http://www.maff.gov.kh


